អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ២០១៤

# សេចក្តីប្រកាសព័ត៌មាន
## កម្មវិធីវិទ្យុប្រចាំសប្តាហ៍របស់ អ.វ.ត.ក
## នឹងចាប់ផ្តើមផ្សាយឡើងវិញនៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ ២០១៤

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នឹងចាប់ផ្តើមដំណើរការឡើងវិញកម្មវិធីវិទ្យុប្រចាំសប្តាហ៍របស់ខ្លួននៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ ២០១៤ បន្ទាប់ពីបានផ្អាករយៈពេលពីរខែ ។ កម្មវិធី "ការជំនុំជម្រះក្តីលើអតីតមេដឹកនាំខ្មែរក្រហម" ផ្សាយផ្ទាល់រៀងរាល់ថ្ងៃព្រហស្បតិ៍ វេលាម៉ោង ១២:០០ - ១៣:០០ រសៀល តាមរយៈរលកធាតុអាកាសនៃស្ថានីយ៍វិទ្យុបាយ័ន FM ៩៥ MHZ ។

កម្មវិធីវិទ្យុនេះនឹងផ្តល់ព័ត៌មានសំខាន់ៗអំពីសវនាការប្រចាំសប្តាហ៍ ហើយវាគ្មិនរបស់តុលាការនឹងពន្យល់លម្អិតអំពីដំណើរវិវឌ្ឍន៍នៃសំណុំរឿង ព្រមទាំងផ្តល់ឱកាសដល់សាធារណជនទូរស័ព្ទចូល ដើម្បីសួរសំណួរទៅកាន់វាគ្មិន ឬ បញ្ចេញទស្សនៈរបស់ខ្លួនជុំវិញការជំនុំជម្រះក្តីខ្មែរក្រហម។

ឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទី នៃ អ.វ.ត.ក បានមានប្រសាសន៍ថា៖ "*កម្មវិធីវិទ្យុរបស់ អ.វ.ត.ក មានបំណងផ្តល់ឱកាសដល់សាធារណជនក្នុងការផ្លាស់ប្តូរមតិយោបល់ជាមួយមន្ត្រីតុលាការ និងទទួលបានការយល់ដឹងប្រសើរជាងមុនអំពីដំណើរការជំនុំជម្រះក្តី ក៏ដូចជាធានាដល់ការទទួលបានព័ត៌មានរបស់សាធារណជន* "។

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh

**លោក ឡាស អូលសិន**
មន្ត្រីផ្នែកច្បាប់
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ ០២៣
សារអេឡិចត្រូនិក: olsenl@un.org